ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 09 / 08 / 2012
ម៉ោង (Time/Heure): 11:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ពុធ ទី ១៨ ខែ កក្កដា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៧៩

រៀបចំដោយ: ឌុច ផារី និង Andrew James MCINTYRE

| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក Andrew James MCINTYRE, លោក ដាវ អានសាន |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ច័ន្ទ តារាស្មី, លោក Tarik ABDULHAK |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZZI, លោក Jasper PAUW |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក ឡោ ជុនធី, លោក វែន ពៅ, លោក សំ សុគង់, លោកស្រី Beini YE, លោកស្រី Christine MARTINEAU, លោកស្រី ទី ស្រីនណា, លោក Olivier BAHOUGNE |
| អ្នកជំនាញ៖ លោក David CHANDLER |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក Simon MEISENBERG, កញ្ញា Julia LEMETAYER, លោកស្រ Robina Struthers, លោក Sheriffo JAMMEH |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.១០ | បញ្ចប់ម៉ោង៖ ១៦.១៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.១០ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖ ១៥.១០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៥ ម៉ោង | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ៩.០៨<br>១២.០៦ | ៩.១១<br>១២.០៦ |
| ការស្នើសុំទទួលស្គាល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ Beine YE | មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង អង្គជំនុំជម្រះ | ៩.១៤ | ៩.១៥ |
| សេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបសសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី | អង្គជំនុំជម្រះ | ៩.១៥ | ៩.២៥ |

| | | | |
|---|---|---|---|
| នួន ជា | | | |
| ការតាំងសំណួរដល់អ្នកជំនាញ David Chandler (TCE-11) | អង្គជំនុំជម្រះ សហព្រះរាជអាជ្ញា | ៩.២៩ ១១.១០ | ១១.១០ ១៦.០០ |
| សំណើស្នើសុំមិនធ្វើសវនាការនៅថ្ងៃសុក្រ ទី ២០ ខែ កក្កដា ឆ្នាំ ២០១២ | មេធាវីការពារក្តី អៀង សារី | ១៦.០៤ | ១៦.០៩ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់</u>**

ជនជាប់ចោទ អៀង សារី (៩.០៨) និង នួន ជា (១២.០៦) តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ (លោក អៀង សារី ស្នើសុំសម្រាប់រយៈពេលពេញមួយថ្ងៃ ហើយលោក នួន ជា ស្នើសុំសម្រាប់ពេលរសៀល)។

**<u>ការស្នើសុំទទួលស្គាល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ</u>** <u>Beine YE</u>

អង្គជំនុំជម្រះសម្រេចទទួលស្គាល់លោកស្រី Beine YE ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ នៅចំពោះមុខ អ.ជ.ស.ដ ហើយលោកស្រីមានសិទ្ធិ និងបុព្វសិទ្ធិដូចមេធាវីជាតិផងដែរ ។

**<u>សេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់សហព្រះរាជអាជ្ញា និង មេធាវីការពារក្តី នួន ជា</u>**

អង្គជំនុំជម្រះសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា (ឯកសារ E126) ដែលបានស្នើសុំដាក់ឯកសារចំនួនពីរនៅចំពោះមុខអង្គជំនុំជម្រះ និងស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីប្រើប្រាស់ឯកសារទាំងនេះនៅពេលតាំងសំណួរដល់សាក្សី TCW-694 ។ អង្គជំនុំជម្រះសម្រេចទទួលយកផ្នែកខ្លះនៃសំណើ ហើយបញ្ជាក់ថាសេចក្តីណែនាំបន្ថែមទៀតនឹងផ្តល់ជូនក្នុងរយៈពេលសមស្រប (សូមមើលសេចក្តីសម្រេចខាងក្រោម)។

អង្គជំនុំជម្រះសម្រេចទទួលយកផ្នែកខ្លះ និងបដិសេធផ្នែកខ្លះនៃសំណើរបស់មេធាវីការពារក្តី នួន ជា (ឯកសារ E172/27/1) ដែលបានស្នើសុំដាក់ឯកសារចំនួន ២០ នៅចំពោះមុខអង្គជំនុំជម្រះ និងស្នើសុំពេលវេលាដើម្បីប្រើប្រាស់ឯកសារនេះសម្រាប់ការសួរដេញដោលអ្នកជំនាញ TCE-11 ។

**<u>ការតាំងសំណួរដល់អ្នកជំនាញ</u>** <u>David Chandler (TCE-11)</u>

អង្គជំនុំជម្រះតាងសំណួរបឋមមួយចំនួនទាក់ទងទៅនឹងអត្តសញ្ញាណរបស់អ្នកជំនាញ បន្ទាប់មកអ្នកជំនាញបានធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ។ អង្គជំនុំជម្រះ និងសហព្រះរាជអាជ្ញាតាំងសំណួរអំពីបញ្ហាសារធាតុដល់អ្នកជំនាញ ។

**<u>សំណើស្នើសុំមិនធ្វើសវនាការនៅថ្ងៃ សុក្រ ទី ២០ ខែ កក្កដា ឆ្នាំ ២០១២</u>**

មេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង សារី ស្នើសុំមិនឱ្យអង្គជំនុំជម្រះធ្វើសវនាការនៅថ្ងៃសុក្រ ទី ២០ ខែ កក្កដា ឆ្នាំ ២០១២ ព្រោះមេធាវីការពារក្តីអន្តរជាតិមានធុរៈមិនអាចចូលរួមបាន។

<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1683 | D108/50/1.75 | 00823678-00823691, 00825418-00825422, 00820987-00820997, 00701668-00701679 00193067-00193488 00726657-00726663, 00825423-00825430, 00824485-00824491 | [Partial T.] ឧបសម្ព័ន្ធ ៧៥៖ សៀវភៅមានចំណងជើងថា សោកនាដកម្មជាប្រវត្តសាស្ត្រនៃប្រទេសកម្ពុជា<br>Annex 75: Book entitled "The Tragedy of Cambodian History"<br>[Partial T.] Annexe 75: Livre de David P. Chandler "The Tragedy of Cambodian History, Politics, War and Revolution since 1945"- Extraits | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/213 | 6.4 | 00823448-00823451, 00823693-00823704, 00075816-00075926 00103989-00104170 00822843-00822853, 00824870-00824877, 00301195-00301304, 00824058-00824059 | កំណត់ហេតុនៃអង្គប្រជុំគណៈ អចិន្ត្រៃយ៍ ស្ដីអំពីគំរោងផែនការ ៤ឆ្នាំ កសាងសង្គមនិយមគ្រប់ផ្នែក ឆ្នាំ១៩៧៧-១៩៨០ ពីថ្ងៃ ២១ ខែ៧ ដល់ថ្ងៃ ២ ខែ៨ ឆ្នាំ១៩៧៦ [Corrected 2] Minutes of the Meeting of the Standing Committee on the Party's Draft of a Four-Year Plan for the Construction of Socialism in all Domains, 1977-1980 dated 21 July to 2 August 1976 [Partial T.] Procès-verbal de la réunion du Comité Permanent au sujet de la planification des plans quadriennaux de la construction du socialisme dans tous les domaines, 1977-1980, du 21 juillet jusqu'au 2 août 1976 | P | 00823693-00823704 | 00103994-00103998, 00104057 | |
| E3/8 | 4.4 | 00823448-00823451, 00823693-00823704, 00075816-00075926 00103989-00104170 00822843-00822853, 00301195-00301304, 00824870-00824877, 00824058-00824059 | កំណត់ហេតុនៃអង្គប្រជុំគណៈ អចិន្ត្រៃយ៍ ស្ដីអំពីគំរោងផែនការ ៤ឆ្នាំ កសាងសង្គមនិយមគ្រប់ផ្នែក ឆ្នាំ១៩៧៧-១៩៨០ ពីថ្ងៃ ២១ ខែ៧ ដល់ថ្ងៃ ២ ខែ៨ ឆ្នាំ១៩៧៦ [Corrected 1] Minutes of the Meeting of the Standing Committee on the Party's Draft of a Four-Year Plan for the Construction of Socialism in all Domains, 1977-1980 dated 21 July to 2 August 1976 [Partial T.] Procès-verbal de la réunion du Comité Permanent au sujet de la planification des plans quadriennaux de la construction du socialisme dans tous les domaines, 1977-1980, du 21 juillet jusqu'au 2 août 1976 | P | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| E3/735 | 18.23 | 00823448-00823451, 00823693-00823704, 00075816-00075926 00103989-00104170 00301195-00301304, 00824058-00824059, 00824870-00824877, 00822843-00822853 | កំណត់ហេតុនៃអង្គប្រជុំគណៈ អចិន្ត្រៃយ៍ ស្ដីអំពីគំរោងផែនការ ៤ឆ្នាំ កសាងសង្គមនិយមគ្រប់ផ្នែក ឆ្នាំ១៩៧៧-១៩៨០ ពីថ្ងៃ ២១ ខែ៧ ដល់ថ្ងៃ ២ ខែ៨ ឆ្នាំ១៩៧៦<br>[Corrected 1] Minutes of the Meeting of the Standing Committee on the Party's Draft of a Four-Year Plan for the Construction of Socialism in all Domains, 1977-1980 dated 21 July to 2 August 1976<br>[Partial T.] Procès-verbal de la réunion du Comité Permanent au sujet de la planification des plans quadriennaux de la construction du socialisme dans tous les domaines, 1977-1980, du 21 juillet jusqu'au 2 août 1976 | P | | | |
| E3/17 | D222/1.3 | 00392897-00393174 | [Surrogate Sheet] CHANDLER David, Brother Number One | P | | | |
| E3/1684 | D108/50/1.4.6 | 00286568-00286575, 00191816-00192089 00182365-00182395, 00192667-00192932 00357247-00357451 | [កែតម្រូវ ១]សំឡេងពីមន្ទីរ ស-២១៖ លិខិតច្បាប់ដើមរបស់ លោកទុំ ជូនអង្គការ<br>Book by DAVID Chandler entitle: "Voices from S-21 - Terror and History in Pol Pot's Secret Prison"<br>Livre écrit par DAVID Chandler intituté:"Pol Pot, Anatomie d'un cauchemar" | P | 00191900, 00191833, 00191846 | 00192742, 00192684, 00192694 | 00357337, 00357267, 00357278 |
| E3/1685 | 4.6 | 00105839-00106011 | សៀវភៅនិពន្ធដោយ David Chandler មានចំណងជើងថា "សម្លេងពីមន្ទីរ ស-២១" | P | | | |
| E3/12 | 6.3 | 00003136-00003142, 00000758-00000764 00182809-00182814 00224363-00224367 | សេចក្ដីសំរេចរបស់គណៈមជ្ឈឹមអំពីបញ្ហាផ្សេងៗមួយចំនួន<br>Decision of central committee on a number of problems<br>Decision of central committee on a number of problems | P | 00003136-3140 | 00182809-814 | 00224363-4367 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/130 | D366/ 7.1.187 | 00442251-00442281<br>00184022-00184047<br>00292914-00292934 | [លិខិតបញ្ជាក់ការជំនួសឯកសារ] លក្ខន្តិកៈ បក្សកុម្មុយនិស្តកម្ពុជា<br>[Surrogate Sheet] The CPK statute<br>[Feuille remplacée] Status du Parti Communiste du Kampuchea | P | Art 27-28, 00442253, 00442255, 00442262, 00442268, 00442264-66, 00442269, 00442277 | Art 27-28, 00184024, 00184025, 00184032, 00184037, 00184034-36, 00184038, 00184045 | Art 27-28, 00292916, 00292917, 00292922, 00292926, 00292923-25, 00292926-27, 00292932 |
| E3/54 | D20 | 00148740-00148744<br>00148814-00148818<br>00148918-00148921 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុចូលខ្លួនតំបូង<br>[Surrogate Sheet] Written Record of Initial appearance of Nuon Chea<br>[Feuille remplacée] Procès verbal de premiere comparution de Nuon Chea | P | 00148742-744 | 00148817 | 00148920-00148921 |
| E3/217 | 13.10 | 00000736-00000743<br>00182635-00182637<br>00334964-00334966 | កំណត់ហេតុអង្គប្រជំគណៈអចិន្ត្រៃយ៍ ថ្ងៃទី ១១ មិនា ១៩៧៦<br>Minutes of permanent committee meeting on 11/3/76<br>Procès-verbal de la réunion du Comité Permanent du 11 mars 1976 | P | 00000736-743 | 00182635-637 | 00334964-966 |
| E3/229 | 13.5 | 00000713-00000720<br>00182625-00182627<br>00334958-00334960 | កំណត់អង្គប្រជុំគណៈអចិន្ត្រៃយ៍យប់ ថ្ងៃទី ២២ កុម្ភៈ ១៩៧៦<br>Minutes of permanent committee meeting on 22 February 1976 at night<br>Procès-verbal de la réunion du Comité Permanent, la nuit du 22 février 1976 | P | | | |
| E3/221 | 13.18 | 00000810-00000826<br>00182693-00182705<br>00386175-00386191 | ពិនិត្យអំពីប្រតិកម្មវៀតណាមក្នុងអង្គប្រជុំលើកទី៥ថ្ងៃទី១៨ ឧសភា ១៩៧៦<br>Observing the Vietnamese reaction in the 5th meeting on 14/5/76<br>Observing the Vietnamese reaction in the 5th meeting on 14/5/76 | P | | | |
| E3/218 | 13.12 | 00000751-00000757<br>00182651-00182657<br>00334967-00334971 | កំណត់ហេតុនៃការប្រជុំគណៈ: អចិន្ត្រៃយ៍ថ្ងៃទី ២៦-០៣-១៩៧៦: លទ្ធផលនៃការចរចាជាមួយវៀតណាម ស្តីពីបញ្ហាព្រំដែនខាងកើត<br>Report of meeting Permanent Commitee on 26-03-1976.: The result of negotiation with Viet Nam about the east border.<br>Rapport de la réunion du Comité Permanent le 26 mars 76: Les résultats des négociations avec les Vietnamiens au sujet des problèmes frontiers de l'Est | P | | 00182657 | |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- សេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់សហព្រះរាជអាជ្ញា និងសំណើរបស់មេធាវីការពារក្តី នួន ជា៖

**<u>សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា (ឯកសារ E126)</u>**៖

អង្គជំនុំជម្រះសម្រេច៖ ឯកសារចំនួនពីរ (D154.2 និង D154.3) ដែលសហព្រះរាជអាជ្ញាបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីប្រើប្រាស់ឯកសារទាំងនេះក្នុងអំឡុងពេលសួរដេញដោលសាក្សី TCW-694 នោះ គឺត្រូវបានប្រើប្រាស់ដោយសហចៅក្រមស៊ើបអង្កេតក្នុងអំឡុងពេលនៃការធ្វើសម្ភាសន៍ជាមួយសាក្សី TCW-694 រួចហើយ។ ហេតុដូច្នេះ ឯកសារទាំងនេះបង្កើតបានជាផ្នែកមួយនៃកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី TCW-694 ។

នៅក្នុងសេចក្តីសម្រេចដែលបានចេញកាលពីពេលមុន (ឯកសារ E142/3 និង E96/7) អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ថា កំណត់ហេតុស្តាប់ចម្លើយនានាកាលពីពេលមុន ដែលសាក្សីរូបនោះនឹងមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ អាចត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ហេតុដូច្នេះ ឯកសារនេះអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះបាន អនុលោមតាមលក្ខណៈវិនិច្ឆ័យនៃវិធាន៨៧(៣)នៃវិធានផ្ទៃក្នុង។

**<u>សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា (ឯកសារ E172/27/1)</u>**៖

អង្គជំនុំជម្រះសម្រេច៖ ឯកសារមួយក្នុងចំណោមឯកសារជាច្រើនដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះដោយក្រុមមេធាវីការពារក្តី នួន ជា គឺមាននៅក្នុងបញ្ជីឯកសាររបស់ភាគីផ្សេងទៀត ហេតុដូច្នេះ មេធាវីការពារក្តី នួន ជា អាចដាក់ឯកសារនេះនៅចំពោះមុខអង្គជំនុំជម្រះបាន ។ ចំពោះឯកសារផ្សេងទៀត ដែលមេធាវីការពារក្តី នួន ជា បានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនោះ គឺមិនមាននៅក្នុងបញ្ជីឯកសាររបស់ភាគីផ្សេងទៀតនោះទេ ហើយភាគច្រើននៃឯកសារទាំងនោះមិនមានជាភាសាខ្មែរ ឬបារាំង និងជាការបោះពុម្ពផ្សាយ ដែលនិពន្ធដោយអ្នកជំនាញ TCE-11 ឬក្នុងនាមគាត់ជាអ្នកផ្តល់បទសម្ភាសន៍ ហើយដែលឯកសារទាំងនេះមានកាលបរិច្ឆេទតាំងពីឆ្នាំ១៩៧៩ មករហូតដល់ខែមីនា ឆ្នាំ ២០១២។

អង្គជំនុំជម្រះបានគ្រោងពេលវេលាស្តាប់សក្ខីកម្មរបស់អ្នកជំនាញ David Chandler នៅថ្ងៃទី ២៥ ខែ

ឧសភា ឆ្នាំ ២០១២ (ឯកសារ E172/24)។ ដូច្នេះ សំណើរបស់ក្រុមការពារក្តីនេះ មិនអាចត្រូវបានពិចារណាថា ធ្វើឡើងដោយ "ទាន់ពេលវេលា" ស្របតាមការសម្រេចរបស់អង្គជំនុំជម្រះនៅក្នុងអនុស្សរណៈ E199 ឡើយ។

លើសពីនេះទៀត ក្រុមមេធាវីការពារក្តី នួន ជា មិនបានពន្យល់ឲ្យបានលម្អិតគ្រប់គ្រាន់ អំពីពេលវេលា និងដោយមធ្យោបាយអ្វី ដែលខ្លួនរកបានឯកសារទាំងនេះ ដោយហេតុនេះ អង្គជំនុំជម្រះមិនអាចធ្វើការវិភាគដឹងបានអំពីកិច្ចប្រឹងប្រែងក្នុងការទទួលបានឯកសារទាំងនេះ ថាតើត្រូវបានធ្វើឡើងកាលពីដើមដំបូងមក ឬយ៉ាងណានោះទេ។ ដូច្នេះ ក្រុមមេធាវីការពារក្តី នួន ជា មិនបានបំពេញតាមការតម្រូវនៃវិធាន ៨៧(៤) ឡើយ។

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ អៀង សារី (០៩.០៨) និង នួន ជា (១២.០៦) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនិងកំណត់ហេតុនេះ)។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា, អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២។ ប្រសិនបើជនជាប់ចោទ អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ អង្គជំនុំជម្រះនឹងសម្រេចលើសំណើសុំរបស់គាត់ជាមុន ។
- បង្គាប់ឲ្យនាំអ្នកជំនាញ David Chandler ទៅកាន់កន្លែងស្នាក់នៅរបស់គាត់ និងបង្គាប់ឲ្យនាំគាត់ត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក ថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ ២០១២ ។

| <u>**កាលបរិច្ឆេទបន្តសវនាការ៖**</u> |
| --- |
| សវនាការនឹងបន្តនៅថ្ងៃ ព្រហស្បត្តិ៍ ទ ១៩ ខែ កក្កដា ឆ្នាំ ២០១២ វេលាម៉ោង ០៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ឌុច ឆាវ** Andrew James MCINTYRE